ពិធីសារនៃ

# ឧបករណ៍មិនបង្កទំនាស់

របស់ចលនាទម្លុះ

2023

# ពិធីសារនៃឧបករណ៍មិនបង្កទំនាស់របស់ចលនាទម្លុះ

## អំពីចលនាទម្លុះ

ពួកយើង គឺជាក្រុមស្ត្រីវ័យក្មេង ដែលធ្វើការដើម្បីលើកកម្ពស់សមភាពយេនឌ័រ នៅប្រទេសកម្ពុជា តាមរយៈការប្រាប់រឿងរ៉ាវ និងចែករំលែករឿងរ៉ាវនិងបទពិសោធន៍។ ពួកយើងរួមគ្នាលើកឡើងអំពីកង្វល់របស់ពួកយើង ទាក់ទងនឹង គម្លាតនៃសមភាពយេនឌ័រ ជម្នះបទដ្ឋានសង្គមដែលរឹតត្បិត និងពង្រឹងភាពអង់អាចរបស់ស្ត្រី និងក្មេងស្រី ជាពិសេសនៅក្នុងប្រទេសកម្ពុជា។

## ទស្សនវិស័យរបស់ចលនាទម្លុះ

គុណតម្លៃស្នូលរបស់ចលនាទម្លុះ រួមមាន ស្ត្រីនិយម និងការសម្រេចបាននូវសមភាពចំពោះស្ត្រីនិងក្មេងស្រីគ្រប់កម្រិតទាំងអស់ ក្នុងសង្គមកម្ពុជា។ ចលនាទម្លុះ ចង់ឱ្យសង្គមកម្ពុជា ក្លាយជាទីកន្លែងមួយ ដែលសិទ្ធិស្ត្រីត្រូវបានគោរព ហើយបទដ្ឋានសង្គមដែលរឹតត្បិតត្រូវបានលុបបំបាត់ ស្ត្រីនិងក្មេងស្រីអាចរស់នៅដោយគ្មានអំពើហិង្សា និងការរំលោភបំពាន។

## គោលបំណងរបស់ចលនាទម្លុះ

- **បន្លឺសំឡេងរបស់ស្ត្រី៖** ផ្តល់នូវវេទិកាមួយសម្រាប់ស្ត្រីនិងក្មេងស្រី ក្នុងការចែករំលែករឿងរ៉ាវរបស់ពួកគេ និងដើម្បីសិក្សាពីគ្នាទៅវិញទៅមក ព្រមទាំងចែករំលែកបទពិសោធន៍ និងភស្តុតាង តាមរយៈការ ផលិតវីដេអូ និងប្រាប់រឿងរ៉ាវរបស់ស្ត្រី តាមទម្រង់ផ្សេងៗទៀត។
- **ជំនះបទដ្ឋានសង្គមដែលរឹតត្បិតលើស្ត្រីនិងក្មេងស្រី៖** លើកកម្ពស់សមភាពយេនឌ័រ តាមរយៈការជំនះបទដ្ឋានសង្គមដែលរឹតត្បិតលើស្ត្រីនិងក្មេងស្រី ជាពិសេសលុបបំបាត់នូវវប្បធម៌បន្ទោសជនរងគ្រោះ និងការអនុវត្តដែលបំពានលើសិទ្ធិនិងសេរីភាពរបស់ស្ត្រីនិងក្មេងស្រី។
- **ពង្រឹងភាពអង់អាច៖** លើកកម្ពស់ការពង្រឹងភាពអង់អាចដើម្បីទម្លាយភាពស្ងប់ស្ងាត់ និងដើម្បីឱ្យស្រីនិងក្មេងស្រីដើរតួនាទីយ៉ាងសកម្ម ក្នុងការសម្រេចចិត្ត នៅក្នុងគ្រប់កម្រិត នៅក្នុងសង្គមកម្ពុជា។

## បេសកកម្មរបស់ចលនាទម្លុះ

បេសកកម្មរបស់ចលនាទម្លុះ គឺលើកឡើងពីក្តីបារម្ភរបស់យើងអំពីគម្លាតក្នុងសមភាពយេនឌ័រ លើកកម្ពស់សមភាពយេនឌ័រ តាមរយៈការជំនះនឹងបទដ្ឋានសង្គមដែលអវិជ្ជមាន និងពង្រឹងភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី នៅក្នុងប្រទេសកម្ពុជា។

## ហេតុអ្វីចាំបាច់មាន ពិធីសារនៃឧបករណ៍មិនបង្កទំនាស់ ?

- ចលនាទម្លុះ ជឿជាក់ថា មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសុវត្ថិភាព នៅពេលដែលទំនាក់ទំនង ជាមួយពួកយើង ជាមួយបុគ្គល/អង្គការទាំងអស់ជាដៃគូរបស់ពួកយើង និងជាមួយសកម្មភាពរបស់ពួកយើង។ នេះរួមបញ្ចូលទាំង សហស្ថាបនិក អ្នកស្ម័គ្រចិត្ត ដៃគូសហការ ឬអង្គការជាដៃគូ ផលិតករ អ្នកមានឥទ្ធិពលក្នុងប្រព័ន្ធបណ្ដាញសង្គម ប្រធានបទនៃភាពយន្ត ព្រមទាំងអ្នកចូលរួមផងដែរ។
- បង្កើតនូវ គោលការណ៍គ្មានការអត់ឱន ចំពោះទម្រង់នៃការបៀតបៀន ឬអំពើហិង្សាណាមួយ៖ គ្រប់សមាជិកក្រុមទាំងអស់ គួរតែយល់ដឹងអំពីគោលការណ៍គ្មានការអត់ឱន ដែលគួរគូសបញ្ជាក់យ៉ាងច្បាស់អំពី អ្វីទៅជាការបៀតបៀន ឬអំពើហិង្សា និងផលវិបាកនៃការបំពានពិធីសារនេះ។

## តើនរណា ដែលពួកយើងត្រូវការពារពីទំនាស់ ?

- កុមារ៖ មនុស្សគ្រប់រូប ដែលមានអាយុក្រោម ១៨ឆ្នាំ (ទម្លុះ នឹងមិនយកកុមារ ដើម្បីធ្វើជាប្រធានបទសម្រាប់ការប្រាប់រឿងរ៉ាវនោះទេ ប៉ុន្តែមានពេលខ្លះ ក៏អាចមានទំនាក់ទំនងជាមួយពួកគេនៅក្នុងសហគមន៍ដែរ)។
- មនុស្សពេញវ័យដែលងាយរងគ្រោះ៖ ជាពិសេសអ្នកដែលត្រូវការជំនួយពិសេស ដោយសារតែកត្តាអាយុ ភេទ និន្នាការភេទ (LGBTQI+) ពិការភាព ជាតិសាសន៍ផ្សេងៗគ្នា និងការអនុវត្តវប្បធម៌ផ្សេងៗគ្នា។ (ទម្លុះ បានកំណត់គោលដៅ ដែលមានចម្រុះភាពនៃយេនឌ័រ ជនមានពិការភាព និងក្រុមជនជាតិដើមភាគតិច ដែលហៅកាត់ថា "ក្រុមគោលដៅ")។
- បុគ្គលគ្រប់រូប ដែលចូលរួមជាមួយ ទម្លុះ និងសកម្មភាពទាំងអស់របស់ ទម្លុះ ។

## តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការការពារនេះ ?

- មនុស្សគ្រប់រូប មានទំនួលខុសត្រូវក្នុងការការពារសុវត្ថិភាពអ្នកចូលរួម ពីការមានទំនាស់ ជាពិសេស សហស្ថាបនិករបស់ចលនាទម្លុះ (ក្រុមការងារស្នូល) ដៃគូសហការ និងអង្គការដែលគាំទ្រពួកគេ។

## ប្រភេទនៃទំនាស់

យោងទៅលើបទដ្ឋានវប្បធម៌និងសង្គម ក្រុមគោលដៅរបស់សកម្មភាពនៃចលនាទម្លុះ អាចជាជនរងគ្រោះដោយអំពើហិង្សាផ្អែកលើយេនឌ័រ ឬទម្រង់ផ្សេងទៀត ដូចជា៖

- ការរំលោភបំពានលើរាងកាយ
- ការរំលោភបំពានផ្លូវអារម្មណ៍ ឬផ្លូវចិត្ត
- ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ច និង/ឬការបៀតបៀនផ្លូវភេទ
- ការធ្វេសប្រហែស។

ហេតុនេះហើយទើប ចលនាទម្លុះ និងអ្នកពាក់ព័ន្ធផ្សេងទៀត ត្រូវតែអនុវត្តកាតព្វកិច្ចយកចិត្តទុកដាក់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ផ្សេងៗ ជាអប្បបរមា ដល់ក្រុមគោលដៅ និងអ្នកដែលពាក់ព័ន្ធជាមួយសកម្មភាពទាំងអស់។

## តើពិធីសារនេះ អនុវត្តយ៉ាងដូចម្ដេច ?

ការទប់ស្កាត់ និងឆ្លើយតបទៅនឹងឧប្បត្តិហេតុនៃការយាយី ឬអំពើហិង្សា គឺជាផ្នែកមួយដ៏សំខាន់នៃការអនុវត្តពិធីសារនៃ "ឧបករណ៍មិនបង្កទំនាស់"។ ខាងក្រោមនេះ គឺជាសកម្មភាពជាក់លាក់មួយចំនួន ដែលអាចអនុវត្តនៅក្នុងបរិបទនៃចលនាទម្លុះ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការប្រាប់នូវរឿងរ៉ាវ៖

- អនុវត្តការវាយតម្លៃហានិភ័យ ដើម្បីគូសបញ្ជាក់ពីការការពារហានិភ័យ ដែលទាក់ទងនឹងសកម្មភាពរបស់ខ្លួន នៅកន្លែងដែលមានក្រុមគោលដៅ។
- ជ្រើសរើសអ្នកស្ម័គ្រចិត្ត រួមទាំងផលិតករ ដោយស្នើសុំឯកសារយោងឯករាជ្យ មានការផ្ទៀងផ្ទាត់ និងសួរនូវសំណួរការពារ ក្នុងអំឡុងពេលដំណើរនៃការសម្ភាសន៍។
- ធានាថា បុគ្គលគ្រប់រូប គឺតំណាងឱ្យអត្តសញ្ញាណរបស់ ចលនាទម្លុះ និងភស្តុតាងបញ្ជាក់ថា ពួកគេបានយល់អំពីក្រមសីលធម៌ (សូមមើលឧបសម្ព័ន្ធ ក)។
- ធានាថា មានគោលការណ៍ណែនាំស្តីពី ការប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម (សូមមើលឧបសម្ព័ន្ធ ខ) ដើម្បីរក្សាសុវត្ថិភាពដល់អ្នកប្រើប្រាស់នៅលើប្រព័ន្ធអនឡាញ។
- ធានាថា ឯកជនភាព និងសេចក្តីថ្លៃថ្នូររបស់អ្នកដែលមាននៅក្នុងរូបថត វីដេអូ និងខ្សែភាពយន្ត ត្រូវអនុវត្តតាមគោលការណ៍ណែនាំ ដែលមានចែងក្នុងឧបសម្ព័ន្ធ គ និងទម្រង់លិខិតព្រមព្រៀង។
- បង្កើតយន្តការរាយការណ៍សុវត្ថិភាព៖ បុគ្គលដែលជួបប្រទះការបៀតបៀន ឬអំពើហិង្សា អាចរាយការណ៍អំពីឧប្បត្តិហេតុនោះដោយសុវត្ថិភាព។ នេះអាចរាប់បញ្ចូលទាំងប្រព័ន្ធរាយការណ៍ជាលក្ខណៈអនាមិក ឬមានអ្នកទទួលបន្ទុកម្នាក់ ដែលបានទទួលការបណ្តុះបណ្តាល ដើម្បីគ្រប់គ្រងរបាយការណ៍ទាំងនោះ។ អ៊ីម៉ែល Complaint.breakthrough@gmail.com គ្រប់គ្រង ដោយក្រុមការងារទទួលបន្ទុកការពារសុវត្ថិភាពចំនួន ២នាក់ (SFPs) ដែលមានតួនាទីរក្សាការសម្ងាត់នូវរាល់ព័ត៌មានដែលទទួលបានពីការរាយការណ៍។
- អនុវត្តវិធីសាស្ត្រផ្តោតលើអ្នករងគ្រោះ ដោយផ្តល់នូវព័ត៌មានផ្សេងៗ ដូចជា សេវាប្រឹក្សា ឬជំនួយផ្នែកច្បាប់។
- នៅពេលទទួលបានរបាយការណ៍ ក្រុមការងារ SFPs គួរតែចាត់វិធានការភ្លាមៗ ដើម្បីដោះស្រាយស្ថានការណ៍ រួមទាំងការចាប់ផ្តើមការស៊ើបអង្កេត ការគាំទ្រជនរងគ្រោះ និងចាត់វិធានការវិន័យចំពោះជនប្រព្រឹត្តប្រសិនបើចាំបាច់។
- ជំរុញវប្បធម៌នៃការគោរព និងគណនេយ្យភាព៖ ក្រុមការងារទទួលបន្ទុកការពារសុវត្ថិភាព គួរតែទទួលខុសត្រូវចំពោះការប្រកាន់ភ្ជាប់នូវពិធីសារនេះ និងទប់ស្កាត់ក្តីកង្វល់នៃការការពារ។ នេះអាចរួមបញ្ចូលទាំង ការបន្តអប់រំ និងបណ្តុះបណ្តាល ស្តីពី ការព្រមព្រៀង ព្រំដែនកំណត់ និងទំនាក់ទំនងប្រកបដោយការគោរព។

តាមរយៈការធ្វើសកម្មភាពជាក់លាក់ទាំងនេះ ចលនាទម្លុះ អាចបង្កើតបរិយាកាសដែលមានសុវត្ថិភាព និងការគាំទ្រ ដោយមិនមានការរំលោភបំពាន ការកេងប្រវ័ញ្ច ការបៀតបៀន និងអំពើហិង្សា។ វាជាការសំខាន់ក្នុងការកត់សម្គាល់ថា ការទប់ស្កាត់ និងការឆ្លើយតបទៅនឹងក្តីកង្វល់នៃការការពារ ទាមទារឱ្យមានការបន្តខិតខំប្រឹងប្រែង និងបន្តប្តេជ្ញាចិត្ត ពីក្រុមការងារស្នូល។ ពិធីសារនិងនីតិវិធីនេះ គួរតែត្រូវបានពិនិត្យនិងធ្វើបច្ចុប្បន្នភាពទៀងទាត់ ដើម្បីធានាពីប្រសិទ្ធភាព និងគាំទ្រដល់សុខុមាលភាពរបស់បុគ្គលគ្រប់រូប។

# ឧបសម្ព័ន្ធ ក ៖ ក្រមសីលធម៌សម្រាប់អ្នកស្ម័គ្រចិត្ត ដៃគូ និងអ្នកសហការ

ខ្ញុំយល់ថា សកម្មភាពនិងអាកប្បកិរិយារបស់ខ្ញុំ មានសារៈសំខាន់ណាស់ ក្នុងការបង្កើតនូវបរិយាកាសមួយ ដែលមានសុវត្ថិភាព បរិយាប័ន្ន និងពោរពេញដោយការគោរព សម្រាប់បុគ្គលគ្រប់រូបដែលពាក់ព័ន្ធ។ ខ្ញុំយល់ស្រប អនុវត្តតាម ក្រមសីលធម៌ខាងក្រោម៖

## ខ្ញុំនឹង៖

1. គោរពបុគ្គលគ្រប់រូប នៅក្នុងរាល់សកម្មភាពរបស់ ទម្លុះ រួមទាំងមហោស្រពភាពយន្តខ្លី ដោយមិនគិតពីពូជសាសន៍ យេនឌ័រ និន្នាការភេទ ពិការភាព សាសនា ឬលក្ខណៈសម្បត្តិផ្សេងទៀតឡើយ។
2. រក្សាឥរិយាបទ និងអាកប្បកិរិយាប្រកបដោយវិជ្ជាជីវៈ នៅគ្រប់សកម្មភាពទាំងអស់របស់ ទម្លុះ រួមទាំងក្នុងមហោស្រពភាពយន្តខ្លីផងដែរ។
3. អនុវត្តតាមគោលការណ៍ណែនាំ និងការណែនាំ ដែលផ្តល់ដោយ ទម្លុះ និងអ្នករៀបចំកម្មវិធី។
4. រាយការណ៍ពីកង្វល់ ឬឧប្បត្តិហេតុនៃទំនាស់ ឬកំហុសក្រមសីលធម៌ណាមួយ ទៅអ្នកទទួលបន្ទុកការពារសុវត្ថិភាព ឬរាយការណ៍តាមរយៈយន្តការដែលបង្កើតឡើងដោយ ទម្លុះ។
5. លើកកម្ពស់បរិយាកាសដែលមានសុវត្ថិភាពនិងបរិយាប័ន្ន សម្រាប់បុគ្គលគ្រប់រូបដែលពាក់ព័ន្ធនៅក្នុងមហោស្រពភាពយន្តខ្លី។
6. ចូលរួមយ៉ាងសកម្មជាមួយអ្នកចូលរួម ក្រុមការងារស្នូល និងអ្នកស្ម័គ្រចិត្តផ្សេងទៀត ដើម្បីបង្កើតបរិយាកាសមួយ ដែលវិជ្ជមាន និងមានការគាំទ្រ។
7. ចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ និងការគាំទ្រ ដែលផ្តល់ដោយទម្លុះ ដើម្បីបង្កើនជំនាញ និងចំណេះដឹង។
8. អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងអស់ រាប់បញ្ចូលទាំងច្បាប់ដែលពាក់ព័ន្ធនឹងការបៀតបៀន ការរើសអើង និងឯកជនភាព។
9. លើកកម្ពស់បរិយាកាសសុវត្ថិភាពសម្រាប់បុគ្គលគ្រប់រូបដែលពាក់ព័ន្ធនឹងសកម្មភាពរបស់ ទម្លុះ ហើយរាយការណ៍ពីការព្រួយបារម្ភ ឬឧប្បត្តិហេតុនៃទំនាស់ ឬកំហុសណាមួយ ទៅកាន់អ្នកទទួលបន្ទុកការពារសុវត្ថិភាព តាមរយៈអ៊ីម៉ែលរក្សាការសម្ងាត់៖ Complaint.breakthrough@gmail.com ។

## ខ្ញុំនឹងមិន៖

1. ចូលរួមក្នុងសកម្មភាពណា ដែលរើសអើង រំលោភបំពាន ឬប្រមាថ រួមទាំងការប្រើប្រាស់ភាសារើសអើង ឬប្រមាថមើលងាយ។
2. ចែករំលែកព័ត៌មានផ្ទាល់ខ្លួន ឬរឿងរ៉ាវរបស់អ្នកស្ម័គ្រចិត្ត កុមារ ឬមនុស្សពេញវ័យដែលងាយរងគ្រោះ អ្នកចូលរួម ឬអ្នកស្ម័គ្រចិត្តផ្សេងទៀត ដោយគ្មានការយល់ព្រម។
3. ប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម ដើម្បីបង្ហោះខ្លឹមសារណាមួយ ដែលមានលក្ខណៈរើសអើង រំលោភបំពាន ឬប្រមាថមើលងាយ។
4. ប្រព្រឹត្តសកម្មភាពតាមរូបភាពណាមួយ ដែលអាចនាំឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់អ្នកចូលរួម ក្រុមការងារស្នូល ឬអ្នកស្ម័គ្រចិត្តផ្សេងទៀត។
5. ចូលរួមក្នុងសកម្មភាពខុសច្បាប់ ឬសកម្មភាពដែលគ្មានសីលធម៌ណាមួយ រួមទាំងការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង នៅពេលធ្វើការស្ម័គ្រចិត្ត។
6. ប្រើប្រាស់តួនាទីជាអ្នកស្ម័គ្រចិត្ត ដើម្បីផ្សព្វផ្សាយឬលក់ ផលិតផលឬសេវាកម្ម ដែលប្រកួតប្រជែងជាមួយម្ចាស់ឧបត្ថម្ភ ឬដៃគូសហការរបស់មហោស្រពភាពយន្តខ្លី។
7. ព្រងើយកន្តើយចំពោះកង្វល់ ឬឧប្បត្តិហេតុនៃទំនាស់ ឬកំហុសណាមួយ ដែលខ្ញុំអាចធ្វើជាសាក្សី ឬក៏បានដឹងពីរឿងទាំងនោះ។
8. ពេលប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម ខ្ញុំនឹងមិនប្រើប្រាស់៖
    - **ភាសារើសអើង ឬប្រមាថមើលងាយ៖** ការបង្ហោះភាសារើសអើង ឬប្រមាថមើលងាយ ឬឱ្យយោបល់លើ ពូជសាសន៍ យេនឌ័រ និន្នាការភេទ ពិការភាព សាសនា ឬលក្ខណៈសម្បត្តិផ្សេងទៀត គឺមិនអាចទទួលយកបានទេ។
    - **រូបថត ឬវីដេអូមិនសមរម្យ៖** ការបង្ហោះរូបថត ឬវីដេអូដែលនិយាយ ឬធ្វើឱ្យនឹកដល់ការរួមភេទ ហិង្សា ឬបង្ហាញអំពីសកម្មភាពខុសច្បាប់ គឺជាសកម្មភាពមិនសមរម្យ និងអាចធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់មហោស្រពភាពយន្តខ្លី។
    - **ព័ត៌មានសម្ងាត់៖** ការបង្ហោះព័ត៌មានសម្ងាត់អំពី អ្នកចូលរួម ក្រុមការងារស្នូល ឬអ្នកស្ម័គ្រចិត្តផ្សេងទៀត ដោយគ្មានការយល់ព្រម គឺជាការរំលោភលើឯកជនភាព និងអាចបង្កឱ្យមានបញ្ហាផ្នែកផ្លូវច្បាប់។
    - **ទំនាស់ផលប្រយោជន៍៖** ការបង្ហោះខ្លឹមសារដែលអាចបង្កើតជម្លោះផលប្រយោជន៍ ឬធ្វើឱ្យគេយល់ថា មានភាពលំអៀង ឬ អយុត្តិធម៌ ដូចជាការផ្សព្វផ្សាយផលិតផល ឬសេវាកម្ម ដែលប្រកួតប្រជែងជាមួយម្ចាស់ឧបត្ថម្ភ ឬ ដៃគូសហការរៀបចំមហោស្រពភាពយន្តខ្លី គឺជាសកម្មភាពមិនសមរម្យ។
    - **អាកប្បកិរិយាមិនគោរព៖** ការបង្ហោះខ្លឹមសារដែលមិនគោរពដល់អ្នកស្ម័គ្រចិត្ត ក្រុមការងារស្នូល ឬអ្នកចូលរួមផ្សេងទៀត ឬចូលរួមក្នុងជម្លោះតាមប្រព័ន្ធអនឡាញ ឬការសម្លុតគំរាមកំហែង គឺជាសកម្មភាពដែលគ្មានវិជ្ជាជីវៈ ហើយអាចបង្កើតបរិយាកាសហិង្សា។
    - **ការបកស្រាយខុស៖** ការបង្ហោះខ្លឹមសារដែលបង្ហាញពីការបកស្រាយខុសទៅលើ គុណតម្លៃ បេសកកម្ម ឬសកម្មភាពនានារបស់ចលនាទម្លុះ គឺជាសកម្មភាពមិនសមរម្យ និងអាចធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ។

ដោយធ្វើតាម អ្វីដែលគួរធ្វើ និងអ្វីមិនគួរធ្វើទាំងលើ ខ្ញុំយល់ថា ខ្ញុំនឹងជួយបង្កើតឱ្យមានបរិយាកាសវិជ្ជមាន និងសុវត្ថិភាព សម្រាប់បុគ្គលគ្រប់រូប ដែលចូលរួមក្នុងសកម្មភាពរបស់ចលនា ទម្លុះ ដោយប្រកាន់ភ្ជាប់តាមគោលការណ៍ណែនាំ។ ក្នុងករណីដែលខ្ញុំប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ខាងលើ ចលនា ទម្លុះ អាចចាត់វិធានការណ៍តាមការសមស្រប ដូចជា បញ្ចប់រាល់សកម្មភាពរបស់ខ្ញុំដែលពាក់ព័ន្ធជាមួយចលនា ទម្លុះ និងអាចរាយការណ៍ពីបញ្ហាដែលអាចកើតមានទៅកាន់ភ្នាក់ងារផ្សេងទៀត រួមទាំងការអនុវត្តច្បាប់ផងដែរ។ តាមរយៈការរក្សាភ្ជាប់នូវអាកប្បកិរិយាប្រកបដោយការគោរព និងវិជ្ជាជីវៈ ខ្ញុំនឹងជួយលើកកម្ពស់សមភាពនិងបរិយាប័ន្ន សម្រាប់មហោស្រពភាពយន្តខ្លី ប្រកបដោយជោគជ័យ និងមានប្រសិទ្ធិភាពខ្ពស់។

ខ្ញុំបានអាននិងយល់ អំពីក្រមសីលធម៌នេះ ហើយយល់ព្រមអនុវត្តតាមនៅកំឡុងពេលបំពេញតួនាទីការងារស្ម័គ្រចិត្ត ឬចូលរួមក្នុងសកម្មភាពរបស់ទម្លុះ។

ឈ្មោះ៖ ____________________

តួនាទី៖ ____________________

ហត្ថលេខា៖ ____________________

ថ្ងៃខែឆ្នាំ៖ ____________________

# ឧបសម្ព័ន្ធ ខ ៖ គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម

គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម គឺជាវិធាន និងការណែនាំ ដែលបង្ហាញពីរបៀបដែលអ្នកស្ម័គ្រចិត្តគួរប្រើវេទិកាប្រព័ន្ធបណ្ដាញសង្គមប្រកបដោយការទទួលខុសត្រូវ និងវិជ្ជាជីវៈ។ គោលការណ៍ណែនាំសម្រាប់ប្រព័ន្ធបណ្ដាញសង្គម គឺចាំបាច់សម្រាប់ការលើកកម្ពស់រូបភាពវិជ្ជមាននិងបរិយាប័ន្ននៃមហោស្រពភាពយន្តខ្លី និងការពារការបង្កទំនាស់ ឬកំហុសឆ្គងណាមួយ ដែលបណ្ដាលមកពីការប្រើប្រាស់ប្រព័ន្ធបណ្ដាញសង្គមមិនសមរម្យ។ ខាងក្រោមនេះ គឺជាចំណុចសំខាន់ៗ គួរពិចារណាមួយចំនួន សម្រាប់គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម៖

1. គោលបំណង៖ គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម គួរតែមានគោលបំណងច្បាស់លាស់ ពោលគឺលើកកម្ពស់ឥរិយាបថប្រកបដោយវិជ្ជាជីវៈ និងការគោរពនៅលើវេទិកាប្រព័ន្ធបណ្ដាញសង្គម និងដើម្បីធានាថា គុណតម្លៃ និងបេសកកម្ម នៃមហោស្រពភាពយន្តខ្លី ត្រូវបានឆ្លុះបញ្ចាំង នៅគ្រប់សកម្មភាពលើប្រព័ន្ធបណ្ដាញសង្គម។
2. វិសាលភាព៖ គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម គួរតែអនុវត្តចំពោះ ក្រុមការងារស្នូល អ្នកស្ម័គ្រចិត្ត និងអ្នកចូលរួមទាំងអស់ ក្នុងមហោស្រពភាពយន្តខ្លី ហើយគួរតែគ្របដណ្ដប់លើវេទិកាប្រព័ន្ធបណ្ដាញសង្គមទាំងអស់ ដែលប្រើប្រាស់ ដើម្បីផ្សព្វផ្សាយ ឬទំនាក់ទំនងអំពីមហោស្រពភាពយន្តខ្លី។
3. ខ្លឹមសារ៖ គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម គួរតែផ្ដល់ឧទាហរណ៍ជាក់លាក់នៃខ្លឹមសារណាដែលមិន សមរម្យ ដែលអ្នកស្ម័គ្រចិត្តគួរជៀសវាង ដូចជា ភាសារើសអើង ឬ ប្រមាថមើលងាយ រូបថត ឬ វីដេអូមិនសមរម្យ និងព័ត៌មានសម្ងាត់ជាដើម។
4. វិជ្ជាជីវៈ៖ គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម គួរតែសង្កត់ធ្ងន់ពីសារៈសំខាន់នៃការរក្សាភ្ជាប់នូវវិជ្ជាជីវៈ នៅលើវេទិកាប្រព័ន្ធបណ្ដាញសង្គម រួមទាំងការជៀសវាងពីការឈ្លោះប្រកែកគ្នាតាមប្រព័ន្ធអនឡាញ ឬការគំរាមកំហែង និងជៀសវាងនូវឥរិយាបថណាមួយ ដែលអាចធ្វើឱ្យបាត់ភាពជឿជាក់លើមហោស្រពភាពយន្តខ្លី។
5. ការសម្ងាត់៖ គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម គួរតែសង្កត់ធ្ងន់ពីតម្រូវការក្នុងការរក្សាការសម្ងាត់ និងការពារភាពឯកជនរបស់អ្នកចូលរួម ក្រុមការងារស្នូល និងអ្នកស្ម័គ្រចិត្តផ្សេងទៀត។
6. យន្តការរាយការណ៍៖ គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម គួរតែផ្ដល់ព័ត៌មានស្ដីពីការរាយការណ៍អំពីការព្រួយបារម្ភណាមួយ ដែលពាក់ព័ន្ធការប្រើប្រាស់ប្រព័ន្ធបណ្ដាញសង្គមដែលមិនសមរម្យ ដោយផ្ដល់នូវឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នកដែលទទួលបន្ទុក (SFPs) ឬយន្តការរាយការណ៍ ដែលបង្កើតឡើងដោយទម្លុះ។
7. ពិនិត្យ និងធ្វើបច្ចុប្បន្នភាព៖ គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម គួរតែត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីធានាថា ព័ត៌មានទាំងអស់ នៅតែពាក់ព័ន្ធនិងមានប្រសិទ្ធភាព ក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធ បណ្ដាញសង្គម ប្រកបដោយការទទួលខុសត្រូវ និងប្រកបដោយវិជ្ជាជីវៈ។

តាមរយៈការផ្ដល់គោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គមច្បាស់លាស់និងទូលំទូលាយ អ្នកស្ម័គ្រចិត្តនឹងយល់កាន់តែច្បាស់អំពីការទទួលខុសត្រូវ និងការរំពឹងទុករបស់ពួកគេ នៅពេលប្រើប្រាស់វេទិកាប្រព័ន្ធបណ្ដាញសង្គម ដើម្បីផ្សព្វផ្សាយ ឬទំនាក់ទំនងអំពីមហោស្រពភាពយន្តខ្លី។ វាមានសារៈសំខាន់ណាស់ ក្នុងការផ្ដល់នូវគោលការណ៍ណែនាំទាំងនេះ ទៅកាន់អ្នកស្ម័គ្រចិត្ត ហើយផ្ដល់ការគាំទ្រ និងការបណ្ដុះបណ្ដាលជាបន្តបន្ទាប់ ដើម្បីធានាថា អ្នកទាំងអស់គ្នាយល់និងអនុវត្តតាម។ លើសពីនេះទៀត អ្នកស្ម័គ្រចិត្តគួរតែទទួលខុសត្រូវ និងប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំប្រព័ន្ធបណ្ដាញសង្គម ហើយការដាក់ពិន័យសមស្របមួយ គួរតែត្រូវបានបង្កើតឡើង សម្រាប់អនុវត្តពេលមានការប្រព្រឹត្តខុសពីការណែនាំ។ អ្នកស្ម័គ្រចិត្តអាចជួយបង្កើតរូបភាពវិជ្ជមានសម្រាប់មហោស្រពភាពយន្ត និងលើកកម្ពស់សមភាពយេនឌ័រ ដើម្បីរក្សាអាកប្បកិរិយាប្រកបដោយការគោរព និងវិជ្ជាជីវៈនៅពេលដែលប្រើប្រាស់ប្រព័ន្ធបណ្ដាញសង្គម។